**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សេចក្តីជូនដំណឹង

អនុវត្តតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៦១ សសរ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១ ស្តីពីការបញ្ចប់ការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលចាប់ពីថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២១។

ក្រសួងមុខងារសាធារណៈមានកិត្តិយសសូមជម្រាបជូន ថ្នាក់ដឹកនាំក្រសួង អគ្គនាយក អគ្គាធិការ នាយកសាលាភូមិន្ទរដ្ឋបាល និងប្រធានអង្គភាពថ្នាក់ស្មើ ព្រមទាំងប្រធាននាយកដ្ឋានចំណុះទាំងអស់មេត្តាជ្រាបថា ដើម្បីបន្តចូលរួម ប្រយុទ្ធប្រឆាំង នឹងការរាតត្បាតនៃជំងឺកូវីដ-១៩ និងរក្សានិរន្តរភាពការងារ ក្រសួងស្នើសុំឯកឧត្តម លោកជំទាវ លោកស្រី អស់លោកទាំងអស់មេត្តាអនុវត្តតាមសំណូមពរចាំបាច់មួយចំនួនដូចខាងក្រោម៖

១. អង្គភាពនីមួយៗត្រូវចាត់ចែងឱ្យមានមន្ត្រី ដែលមានភារកិច្ចចាំបាច់ឱ្យមកប្រចាំការផ្លាស់វេនគ្នា បំពេញការងារជាប្រក្រតីឡើងវិញ។ ប្រធាន ឬមន្ត្រីប្រគល់សិទ្ធិឱ្យទទួលខុសត្រូវ ចាំបាច់ត្រូវមានវត្តមានជាប្រចាំនៅការិយាល័យក្នុងម៉ោងធ្វើការ។

២. ក្រសួងនឹងរៀបចំឯកសារបញ្ជាបេសកកម្មដើម្បីសម្រួលដល់ការធ្វើដំណើរមកបំពេញការងាររបស់មន្ត្រីដែលបន្តរស់នៅក្នុងតំបន់បិទខ្ទប់នៅឡើយ ទាំងតំបន់ក្រហម និងតំបន់លឿងទុំ។ ទន្ទឹមនឹងនោះ ប្រធានអង្គភាពត្រូវបន្តយកចិត្តទុកដាក់ តាមដាន រក្សាទំនាក់ទំនងព័ត៌មានជាប្រចាំ និងជួយសម្រួលដោះស្រាយនូវបញ្ហាលំបាក ខ្វះខាត ក្នុងជីវភាពរស់នៅរបស់មន្ត្រីក្រោមឱវាទដែលកំពុងស្ថិតនៅក្នុងតំបន់រងផលប៉ះពាល់ពីការបិទខ្ទប់ និងពីវិបត្តិនៃការឆ្លងរាលដាលជំងឺកូវីដ-១៩។

៣. ក្រសួងនឹងបង្កលក្ខណៈសម្រួលជាធម្មតាដល់ការធ្វើដំណើររបស់ថ្នាក់ដឹកនាំ និងមន្ត្រីដែលត្រូវទៅបំពេញភារកិច្ចចាំបាច់នៅក្នុងមូលដ្ឋានតាមបណ្តាខេត្ត ក្រុង។

ក្រសួងមុខងារសាធារណៈសូមសំដែងអំណរគុណដ៏ជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ដែលក្នុងរយៈពេលកន្លងទៅ បានចូលរួមយ៉ាងសកម្ម ប្រកបដោយទឹកចិត្ត យោគយល់ ទ្រាំទ្រជាមួយរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋក្នុងការប្រឈមមុខចំពោះរាល់ផលវិបាកធ្ងន់ធ្ងរបង្កដោយជំងឺកូវីដ-១៩។

យើងទាំងអស់គ្នា មានជំនឿយ៉ាងមុតមាំលើមគ្គុទ្ទេសក៍ដ៏ឈ្លាសវៃ ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដោយជឿជាក់ជាច់ខាតថាយើងពិតជាប្រយុទ្ធឈ្នះកូវីដ-១៩ នាំសង្គមជាតិទៅកាន់ប្រក្រតីភាពជាធម្មតាឡើងវិញក្នុងពេលដ៏ខ្លីខាងមុខនេះ ដើម្បីរក្សាការពារបុព្វហេតុ សុខសន្តិភាព ស្ថិរភាព សុខុមាលភាពរបស់ប្រជាជន និងវិបុលភាពរបស់សង្គមជាតិតទៅអនាគត។

ថ្ងៃ អង្គារ ៥ រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០២១

ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh